ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : [illegible].....ដនស/អសណ

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ ២០១០

ក្រសួងមហាផ្ទៃ
ចូល 799
14.6.10 15:00

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សូមគោរពជូន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ** : សំណើប្រគល់សិទ្ធិជូន **ឯកឧត្តមអភិបាល** ខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងខេត្តព្រៃវែង ចេញដីកាធ្វើប្រតិភូកម្មអំណាចដល់ ក្រុងតាខ្មៅ ក្រុងស្ទឹងសែន ក្រុងក្រចេះ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត ក្រុងសួង និងស្រុកពាមរក៍ អំពីការងារសាងសង់ ។

**យោង** :
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- សេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ ការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ របស់រាជរដ្ឋាភិបាលកម្ពុជា
- លិខិតលេខ ០៣១ លស/គ.ជ.អ.ប ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានស្នើសុំឱ្យគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើប្រតិភូកម្មអំណាចដល់ក្រុងតាខ្មៅខេត្តកណ្តាល ក្រុងក្រចេះខេត្តក្រចេះ ក្រុងស្ទឹងសែនខេត្តកំពង់ធំ ក្រុងព្រះសីហនុខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ក្រុងសួងខេត្តកំពង់ចាម និងស្រុកពាមរក៍ខេត្តព្រៃវែង តាមស្មារតីសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្រសួងបានពិនិត្យ និងសម្រេចលើសេចក្តីណែនាំ ស្តីពីការផ្តល់សេវាសាធារណៈផ្នែកសំណង់ លើការងារសាងសង់អគារលំនៅឋាន ដែលមានផ្ទៃក្រឡាកម្រាលសំណង់មិនលើសពី ៥០០ម² និងមានកម្ពស់មិនលើសពី ២ជាន់ គិតទាំងជាន់ផ្ទាល់ដី របងដែលមានកម្ពស់មិនលើសពី ២ម គិតពីកម្រិតកម្ពស់ដីនៅជើងរបង ។

អាស្រ័យហេតុនេះ យោងតាមមាត្រា ៤ ត្រង់ចំណុច ៤.១ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ដែលបានចែងថា " ខេត្ត ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ក្រោមការទទួលខុសត្រូវរបស់ខ្លួន " សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតជូនអភិបាលខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងខេត្តព្រៃវែង ចេញដីកាធ្វើប្រតិភូកម្មអំណាចជូនក្រុងតាខ្មៅ ក្រុងស្ទឹងសែន ក្រុងក្រចេះ ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត ក្រុងសួង និងស្រុកពាមរក៍ លើការងារសាងសង់តាមស្មារតីខាងលើ និងទៅតាមនីតិវិធី ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងចេញសេចក្តីណែនាំ និងកំណត់ចំណូលពីសោហ៊ុយលើសេវាសំណង់ ដើម្បីឱ្យក្រុង ស្រុកគោលដៅទាំងប្រាំពីរ មានមូលដ្ឋានក្នុងការអនុវត្ត ។

សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : .០៨...........សណន

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១០

# សេចក្តីណែនាំ

## ស្តីពី

## ការផ្តល់សេវាសាធារណៈផ្នែកសំណង់ នៅក្រុងតាខ្មៅខេត្តកណ្តាល ក្រុងស្ទឹងសែនខេត្តកំពង់ធំ ក្រុងក្រចេះខេត្តក្រចេះ ក្រុងព្រះសីហនុខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ក្រុងសួងខេត្តកំពង់ចាម និងស្រុកពាមរក៍ខេត្តព្រៃវែង

ក្នុងគោលបំណងលើកស្ទួយប្រសិទ្ធភាពសេវាសាធារណៈលើផ្នែកសំណង់ នៅក្រុងតាខ្មៅខេត្តកណ្តាល ក្រុងស្ទឹងសែនខេត្តកំពង់ធំ ក្រុងក្រចេះខេត្តក្រចេះ ក្រុងព្រះសីហនុខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ក្រុងសួងខេត្តកំពង់ចាម និងស្រុកពាមរក៍ ខេត្តព្រៃវែង ស្របតាមស្មារតីនៃសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចតទៅ :

### I- ការផ្តល់លិខិតអនុញ្ញាត

១. ដោយអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងក្នុងពេលដែលពុំទាន់មានប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី សាលាក្រុងតាខ្មៅ សាលាក្រុងស្ទឹងសែន សាលាក្រុងក្រចេះ សាលាក្រុងព្រះសីហនុ សាលាក្រុងប៉ោយប៉ែត សាលាក្រុងសួង និងសាលាស្រុកពាមរក៍ ត្រូវបានផ្តល់នូវសមត្ថកិច្ចពិនិត្យ និងផ្តល់សេវាសាធារណៈផ្នែកសំណង់ដូចខាងក្រោម :

- លិខិតអនុញ្ញាតសាងសង់ ឬ លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ចំពោះបណ្តាសំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសរុបមិនលើសពី ៥០០ ( ប្រាំរយ) ម៉ែត្រការ៉េ និងមានកម្ពស់មិនលើសពី ០២ ( ពីរ ) ជាន់ គឺជាន់ផ្ទាល់ដី និងជាន់ទី ១
- លិខិតអនុញ្ញាតសាងសង់ ឬ លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម ជួសជុលរបងដែលមានកម្ពស់មិនលើសពី ០២ ( ពីរ ) ម៉ែត្រ គិតពីកម្រិតកម្ពស់ដីនៅជើងរបង
- លិខិតអនុញ្ញាតបើក និងបិទការដ្ឋាន ចំពោះបណ្តាសំណង់ដែលសាលាក្រុង ស្រុក បានចេញលិខិតអនុញ្ញាតសាងសង់ សាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ឬ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវចំពោះបណ្តាសំណង់ដែលសាលាក្រុង ស្រុក បានផ្តល់លិខិតអនុញ្ញាតសាងសង់

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel/Fax : (855-23) 215 660 , e-mail : mlmupc@ Camnet. Com,kh

- លិខិតផ្អាកការសាងសង់ចំពោះរាល់សកម្មភាពសាងសង់ដែលមិនគោរពតាមបទប្បញ្ញត្តិជាធរមាន ។

២. រាល់ការស្នើសុំ ចំពោះបណ្តុំសំណង់ដែលមានផ្ទៃក្រឡាកម្រាលធំជាងការកំណត់ក្នុងចំណុចទី ១ ខាងលើ សាលាក្រុង ស្រុក ត្រូវពិនិត្យ និងផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយសំណុំឯកសារនៃពាក្យសុំជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ។

៣. សាលាក្រុង ស្រុក នឹងត្រូវទទួលបានពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីនូវច្បាប់ចម្លងចំនួនមួយច្បាប់ នៃលិខិតអនុញ្ញាតសាងសង់ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ ដោយសាលារាជធានី ខេត្ត ។

## II - សំណុំឯកសារនៃពាក្យសុំ

រាល់សំណុំឯកសារ និងទម្រង់បែបបទនៃពាក្យសុំ ត្រូវអនុវត្តដូចខាងក្រោម :

១. ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ឬលិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ត្រូវអនុវត្តតាមមាត្រា ៩ ជំពូកទី ៣ និងមាត្រា ២២ ជំពូកទី ៥ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ។ គំរូ នៃពាក្យសុំនេះ និងទម្រង់បែបបទផ្សេងទៀត មាននៅក្នុង ***ឧបសម្ព័ន្ធទី ១*** ។

២. ពាក្យសុំលិខិតអនុញ្ញាតបើក ឬបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ត្រូវអនុវត្តតាមប្រការ ៣ ប្រការ ១១ និងប្រការ ១២ នៃប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ។ គំរូ នៃពាក្យសុំទាំងនេះ និងទម្រង់បែបបទផ្សេងទៀត មាននៅក្នុង ***ឧបសម្ព័ន្ធ ទី ២ និងទី ៣*** ។

## III - សោហ៊ុយលើសេវាសំណង់

សោហ៊ុយលើសេវាសំណង់សម្រាប់សាលាក្រុងតាខ្មៅខេត្តកណ្តាល ក្រុងស្ទឹងសែនខេត្តកំពង់ធំ ក្រុងក្រចេះខេត្តក្រចេះ ក្រុងព្រះសីហនុខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ក្រុងសួងខេត្តកំពង់ចាម និងស្រុកពាមរក៍ខេត្តព្រៃវែង មាននៅក្នុង***ឧបសម្ព័ន្ធ ទី ៤*** ។ ចំពោះសោហ៊ុយលើសេវាសំណង់នេះ សាលាក្រុង ស្រុក ទាំងប្រាំពីរត្រូវអនុវត្តឱ្យមានតម្លាភាពដោយមានការកត់ត្រាក្នុងបញ្ជីច្បាស់លាស់តាមគោលការណ៍ដែលបានកំណត់ដោយក្រសួងមានសមត្ថកិច្ច ។

## IV - នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត

១. ការដាក់សំណុំឯកសារនៃពាក្យសុំ និងការធ្វើទំនាក់ទំនងទទួលព័ត៌មានពាក់ព័ន្ធ ត្រូវប្រព្រឹត្តទៅនៅការិយាល័យច្រកចេញចូលតែមួយ នៃផ្នែកជួរមុខរបស់សាលាក្រុង ស្រុក ។ ការិយាល័យច្រកចេញចូលតែមួយត្រូវទទួលរាល់សំណុំឯកសារនៃពាក្យសុំដែលមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ការទទួលពាក្យសុំត្រូវចុះកាលបរិច្ឆេទ ( ថ្ងៃ ខែ ឆ្នាំ ម៉ោង ) និងចេញបង្កាន់ដៃទទួលពាក្យ ។

២. ការត្រួតពិនិត្យសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ របស់សាលាក្រុង ស្រុក មានរយៈពេល ១៥ (ដប់ប្រាំ ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយឡែកចំពោះសំណុំឯកសារនៃពាក្យសុំផ្សេងទៀត រយៈពេលនៃការត្រួតពិនិត្យត្រូវតិចជាង អាស្រ័យទៅតាមស្ថានភាពនៃសំណើ ។ រយៈពេលត្រួតពិនិត្យរាល់សំណុំឯកសារ នៃពាក្យសុំត្រូវគិតចាប់ពីថ្ងៃដែលចេញបង្កាន់ដៃទទួលសំណុំឯកសារនៃពាក្យសុំ ។

៣. រាល់ការសម្រេចលើពាក្យសុំលិខិតអនុញ្ញាតនានា ត្រូវអនុវត្តតាមបែបបទរដ្ឋបាលរបស់សាលាក្រុង ស្រុក ទាំងប្រាំពីរ បន្ទាប់ពីបានទទួលយោបល់របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ។

៤. សាលាក្រុង ស្រុក ត្រូវបញ្ជូនច្បាប់ចម្លងនៃរាល់លិខិតអនុញ្ញាតដែលផ្តល់ដោយសាលាក្រុង ស្រុក និងឯកសារពាក់ព័ន្ធចំនួនមួយច្បាប់ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ។

## V- ការតាមដានត្រួតពិនិត្យសកម្មភាពសាងសង់

រាល់ការសាងសង់ ដូចមានកំណត់ក្នុងចំណុច (I) ខាងលើ សាលាក្រុង ស្រុក ត្រូវសហការជាមួយការិយាល័យជំនាញដើម្បីតាមដាន ត្រួតពិនិត្យសកម្មភាពសាងសង់ ។ រាល់ការសាងសង់ដែលមានផ្ទៃក្រឡាកម្រាលធំជាង ឬ ខុសពីប្រភេទសំណង់ដែលបានកំណត់ក្នុងចំណុច (I) ដែលស្ថិតនៅក្នុងក្រុង ស្រុក សាលាក្រុង ស្រុក ត្រូវសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្នុងការតាមដានត្រួតពិនិត្យសកម្មភាពសាងសង់ជាប្រចាំ និងចាត់វិធានការជាក់ស្តែងចំពោះរាល់សកម្មភាពមិនប្រក្រតី ។

## VI- នគរូបនីយប្បញ្ញត្តិ

ដើម្បីមានមូលដ្ឋានសម្រាប់អនុវត្តក្នុងការផ្តល់លិខិតអនុញ្ញាតនានា សាលាក្រុង ស្រុកទាំងប្រាំពីរ ត្រូវសហការជាមួយស្ថាប័នមានសមត្ថកិច្ចរៀបចំប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី ព្រមទាំងនគរូបនីយប្បញ្ញត្តិនៅមូលដ្ឋានរបស់ខ្លួនសម្រាប់ប្រើប្រាស់ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សង្ឃឹមលើស្មារតីទទួលខុសត្រូវក្នុងការអនុវត្តសេចក្តីណែនាំនេះ តាមភារកិច្ចរៀងៗខ្លួន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- លេខាធិការដ្ឋាន គជ.អ.ប
- សាលាខេត្តកណ្តាល សាលាខេត្តកំពង់ធំ សាលាខេត្តក្រចេះ សាលាខេត្តព្រះសីហនុ សាលាខេត្តបន្ទាយមានជ័យ សាលាខេត្តកំពង់ចាម សាលាខេត្តព្រៃវែង
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល កំពង់ធំ ក្រចេះ ព្រះសីហនុ បន្ទាយមានជ័យ កំពង់ចាម និងព្រៃវែង
- សាលាក្រុង ស្រុក ទាំង៧
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

# សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាត
# សាងសង់ ពង្រីកបន្ថែម រុះរើ និងជួសជុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំលិខិតអនុញ្ញាតសាងសង់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ .............................. ភេទ ......... អាយុ ........ ឆ្នាំ សញ្ជាតិ ........... មុខរបរ.....................
អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ......................... ផ្លូវលេខ .....................ក្រុមទី .............. ភូមិ.............................
ឃុំ/សង្កាត់................................ស្រុក/ក្រុង ...........................ខេត្ត ........................... ទូរស័ព្ទលេខ .........................
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .........................................................................................................។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ .............................. ភេទ ......... អាយុ ........ ឆ្នាំ សញ្ជាតិ ........... មុខរបរ.....................
អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ......................... ផ្លូវលេខ .....................ក្រុមទី .............. ភូមិ.............................
ឃុំ/សង្កាត់..................................ស្រុក/ក្រុង ................................ខេត្ត ..........................ទូរស័ព្ទលេខ .........................
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .........................................................................................................។

**សូមគោរពជូន**

**លោក អភិបាលក្រុង** ..................................................................................

**តាមរយៈ** : លោកចៅសង្កាត់ ...............................................................................................................

**កម្មវត្ថុ** : សំណើសុំលិខិតអនុញ្ញាត ...................................................................................................

ស្ថិតនៅលើដីឡូត៍លេខ ..........................ផ្លូវលេខ .................... ក្រុមទី ............. ភូមិ.....................
សង្កាត់ ........................ ក្រុង ............................... ខេត្ត .................................... ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបលោកអភិបាលក្រុង មេត្តាជ្រាបថខ្ញុំបាទ-នាងខ្ញុំ
មានបំណង ................................................ ស្ថិតនៅលើដីឡូត៍លេខ ...................................ផ្លូវលេខ ........................
ក្រុមទី ........... ភូមិ ..........................សង្កាត់ ............................ ក្រុង............................ ខេត្ត ..............................។

អាស្រ័យហេតុនេះ សូមលោកអភិបាលក្រុង មេត្តាពិនិត្យ និងផ្តល់លិខិតអនុញ្ញាត ......................................
ដោយក្តីអនុគ្រោះ ។

........................ ថ្ងៃទី .......ខែ .......... ឆ្នាំ ...........

**ស្នាមមេដៃស្តាំ**

លេខ : ......................

**បានឃើញ និងបញ្ជូនមក**

**លោកអភិបាលក្រុង** ...............................**មេត្តាពិនិត្យ និងសំរេច ។**

........................ ថ្ងៃទី ............... ខែ .............. ឆ្នាំ ................

**ចៅសង្កាត់** ...................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាអ្នកជាប់ព្រំ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ...................................... ភេទ ......... អាយុ ........ ឆ្នាំ សញ្ជាតិ ........... មុខរបរ...........................
អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ .......................... ផ្លូវលេខ ......................ក្រុមទី .............. ភូមិ......................................
ឃុំ/សង្កាត់....................................ស្រុក/ក្រុង.................................ខេត្ត .................................. ដែលមានព្រំដីឡូត៍ផ្នែកខាង
......................................................... ជាប់ជាមួយដីឡូត៍ដែលត្រូវសាងសង់លេខ ....................................... ក្រុមទី .........
ភូមិ............................ សង្កាត់....................................ក្រុង ...........................................ខេត្ត ...............................
របស់លោក-លោកស្រី ....................................................................................................... ។

បានយល់ព្រមឱ្យលោក-លោកស្រី .....................................................................................................
សាងសង់ ....................................................................................................ជាប់ព្រំដីឡូត៍របស់ខ្ញុំបាទ-នាងខ្ញុំ ដោយ :
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................

ក្រែងពុំពិតប្រាកដ យើងខ្ញុំ សូមផ្តិតមេដៃស្តាំ ទុកជាភស្តុតាងស្រាប់ ។

..............................ថ្ងៃទី ......... ខែ.........ឆ្នាំ ..............

**ស្នាមមេដៃអ្នកស្នើសុំ** **ស្នាមមេដៃអ្នកអនុញ្ញាត**

លេខ : ........................

**បានឃើញ និងបញ្ជាក់ថា**

**ស្នាមមេដៃខាងលើ ពិតជាស្នាមមេដៃរបស់**

**លោក ..................................... និងលោក**

**.......................................ប្រាកដមែន ។**

.............................. ថ្ងៃទី.............. ខែ .............. ឆ្នាំ ....................

**ចៅសង្កាត់** ...................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាសាងសង់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ...................................... ភេទ ......... អាយុ ......... ឆ្នាំ សញ្ជាតិ ............... អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ............................ ផ្លូវលេខ .....................ក្រុមទី ......... ភូមិ........................ ឃុំ/សង្កាត់............................ ស្រុក/ក្រុង................................................ខេត្ត .................................................... ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ......................................... ភេទ ......... អាយុ ........... ឆ្នាំ សញ្ជាតិ ........... អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ........................................... ផ្លូវលេខ ....................ក្រុមទី .......................... ភូមិ................................. ឃុំ/សង្កាត់.............................................. ស្រុក/ក្រុង .......................................ខេត្ត .................................................. ។

## សូមធ្វើកិច្ចសន្យា ដូចតទៅ :

១- គោរពតាមខ្លឹមសារដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៨៦ អនក្រ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ។

២- ធានាសុវត្ថិភាពដល់អ្នកជិតខាង ដែលមានសំណង់បានសាងសង់មុន ។

៣- ធានាមិនឱ្យកាកសំណល់ ទឹកកខ្វក់ប៉ះពាល់ដល់បរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋជុំវិញ ឬទីសាធារណៈឡើយ ។

៤- ធានាការពារមិនឱ្យមានអគ្គិភ័យកើតមានឡើង ដោយសារការសាងសង់របស់ខ្ញុំបាទ-នាងខ្ញុំ ។ ក្នុងករណីកើតមានអគ្គិភ័យជាយថាហេតុណាមួយ ខ្ញុំបាទ-នាងខ្ញុំ យល់ព្រមចេញសងនូវការខូចខាតទាំងឡាយរបស់អ្នកនៅជិតខាងនោះ ។

៥- ក្នុងករណីទៅថ្ងៃក្រោយ បើមានការប៉ះពាល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន ឬការពង្រីកផ្លូវ ខ្ញុំបាទ-នាងខ្ញុំ សុខចិត្តគោរពតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល ។

ខ្ញុំបាទ-នាងខ្ញុំ សូមសន្យាថា នឹងគោរពតាមកិច្ចសន្យានេះទាំងស្រុង ហើយសូមទទួលខុសត្រូវចំពោះមុខច្បាប់របស់រដ្ឋ ក្នុងករណីប្រព្រឹត្តខុសពីកិច្ចសន្យាខាងលើ ។

.................................ថ្ងៃទី ......... ខែ..........ឆ្នាំ ..............

**ស្នាមមេដៃស្តាំម្ចាស់សំណង់**

លេខ : ......................

**បានឃើញ និងបញ្ជាក់ថា**

**ស្នាមមេដៃខាងលើ ពិតជាស្នាមមេដៃរបស់**

**លោក** .................................. **និងលោក**

......................................**ប្រាកដមែន ។**

.............................. ថ្ងៃទី ............... ខែ .............. ឆ្នាំ ................

**ចៅសង្កាត់** ................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ...................................... ភេទ ........ អាយុ ........ ឆ្នាំ សញ្ជាតិ ................ មុខរបរ.........................
អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ............................. ផ្លូវលេខ .........................ក្រុមទី ......... ភូមិ.....................................
ឃុំ/សង្កាត់............................ ស្រុក/ក្រុង ............................ខេត្ត ............................... ទូរសព្ទលេខ ..............................
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .......................... .......................................................................។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ...................................... ភេទ ............ អាយុ .......ឆ្នាំ សញ្ជាតិ .......... មុខរបរ .........................
អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ....................................... ផ្លូវលេខ ............................... ក្រុមទី ........
ភូមិ............................................ ឃុំ/សង្កាត់......................................... ស្រុក/ក្រុង ..................................................
ខេត្ត ....................................................... ទូរសព្ទលេខ ................................................... អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ
.........................................................................។

ខ្ញុំបាទ-នាងខ្ញុំ សូមសន្យាជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ថា នឹងអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវចំណុចខាងក្រោម :

១- ធ្វើរបងហ៊ុំពទ្ធ័ការដ្ឋានសំណង់ និងធ្វើរបាំង ឬ សំណាញ់ការពារ ពីក្រោមដល់លើ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ ។

២- រក្សាទុកចិញ្ចើមថ្នល់ឱ្យបានទូលាយ ស្មើនឹងពីរភាគបី នៃចិញ្ចើមថ្នល់ ដែលមានស្រាប់ សំរាប់ចរាចរណ៍សាធារណៈ ។

៣- មិនយកទ្រូងផ្លូវធ្វើជាកន្លែងលាយស៊ីម៉ង់ត៍ ចាក់សំរាម កំទេចកំទី ដាក់សម្ភារៈសំណង់ដូចជា គ្រួស ខ្សាច់ ថ្ម ឥដ្ឋ ... ។ល។ ដែលធ្វើឱ្យប៉ះពាល់ដល់អនាម័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

៤- មិនបង្កទំនាស់ និងរំខានដល់អ្នកជិតខាងដែលជាប់ដីឡូត៍គ្នា ។

៥- រៀបចំការពារសុវត្ថិភាពការដ្ឋាន និងសុវត្ថិភាពដល់ពលករក្នុងការដ្ឋាន ពេលប្រតិបត្តិការងារសាងសង់ ។

ក្នុងករណីមិនគោរព និងមិនអនុវត្តតាមកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។ ក្រែងពុំប្រាកដ ខ្ញុំបាទ-នាងខ្ញុំ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាង ។

................................ថ្ងៃទី ......... ខែ.........ឆ្នាំ ..............

**ស្នាមមេដៃស្តាំ**

លេខ : .......................

**បានឃើញ និងបញ្ជាក់ថា**

**ស្នាមមេដៃនេះ ពិតជាស្នាមមេដៃរបស់**

**លោក** ..................................... **និងលោក**

................................................**ប្រាកដមែន ។**

.............................. ថ្ងៃទី .............. ខែ .............. ឆ្នាំ ...................

**ចៅសង្កាត់** ..................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យារបស់ក្រុមហ៊ុន ឬក្រុមជាងសាងសង់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ............................................ ភេទ ........ អាយុ ........ ឆ្នាំ សញ្ជាតិ ............... ជាតំណាងក្រុមហ៊ុន សាងសង់ ឬក្រុមជាងសំណង់............................................ អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ....................................... ផ្លូវលេខ .................. ក្រុមទី .............. ភូមិ................................. ឃុំ/សង្កាត់.............................................................. ស្រុក/ក្រុង .......................... ខេត្ត ...................................... ទូរសព្ទលេខ ................................................................ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .......................................វិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់លេខ.................................. ដែលចេញដោយ ....................................................... បានយល់ព្រមទទួលម៉ៅការ ........................................................ របស់លោក-លោកស្រី ..................................................... នៅលើដីឡូត៍លេខ ........................................................... ផ្លូវលេខ .......................................ក្រុមទី ............. ភូមិ.................................... .....សង្កាត់............................................... ក្រុង ...........................................ខេត្ត .........................................។

ខ្ញុំបាទ-នាងខ្ញុំសូមសន្យាថា :

- គោរព និងអនុវត្តតាមការណែនាំរបស់ម្ចាស់សំណង់ និងស្របតាមបទប្បញ្ញត្តិ ច្បាប់ជាធរមាន ។
- អនុវត្តតាមប្លង់គ្រឿងផ្គុំសំណង់ និងប្លង់ស្ថាបត្យកម្ម ដែលបានអនុញ្ញាត ។
- ទទួលខុសត្រូវលើការងារបច្ចេកទេសសាងសង់ លើគុណភាព និងសុវត្ថិភាពសំណង់ ដែលសហគ្រាស ក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់បានអនុវត្ត ។

.................................ថ្ងៃទី ......... ខែ.............ឆ្នាំ ..............

**ក្រុមហ៊ុនសាងសង់ ឬ ក្រុមជាងសំណង់**

**ប្រធាន**

**បានឃើញ និងឯកភាព**

**ម្ចាស់សំណង់**

**ជូនភ្ជាប់ :**

- វិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ចំនួន ០១ច្បាប់ ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : .................. ជនសក.....

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

**បញ្ជូនមកលោកអភិបាល ក្រុង-ស្រុក មេត្តាពិនិត្យ និង សម្រេច**

.............ថ្ងៃទី ............ ខែ ............ ឆ្នាំ ..........

**ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង-ស្រុក........**

## បទបញ្ជា

ដើម្បីរក្សានូវសណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព របស់ក្រុង-ស្រុក និង ធានានូវគុណភាព និងសុវត្ថិភាពរបស់សំណង់ យោងតាមអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និង អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង សេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និង ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ របស់រាជរដ្ឋាភិបាល

ម្ចាស់សំណង់ត្រូវ :

១-មានលិខិតអនុញ្ញាតបើកការដ្ឋាន មុនពេលសាងសង់ពីសាលា ក្រុង-ស្រុក ........................................................ ។

២-អនុវត្តតាមប្លង់លម្អិតគ្រឿងផ្គុំសំណង់ ក្នុងការសាងសង់ និង គោរពតាមប្លង់ស្ថាបត្យកម្ម ដែលបានយល់ ព្រមដោយសាលា ក្រុង-ស្រុក.............................................................. ។

៣-រក្សាសុវត្ថិភាពនៅពេលសាងសង់ដល់អគារជិតខាង និង ធានាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈ ដូចជា ករណីធ្វើរបងហ៊ុំព័ទ្ធជុំវិញការដ្ឋាន ការទុកដាក់គ្រឿងចក្រ ឬ សម្ភារៈសំណង់ និងការងារអនាម័យជាដើម ។

៤-មានលិខិតបិទការដ្ឋាន ឬ វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ពីសាលា ក្រុង-ស្រុក ...................................... ក្រោយពេលសាងសង់រួចជាស្ថាពរ មុនដំណើរការប្រើប្រាស់សំណង់។

ខ្ញុំបាទ-នាងខ្ញុំ ............................................... សូមគោរពតាមបទបញ្ជា ដូចមានចែងខាងលើ ដោយឥតល័ក្ខខ័ណ្ឌ។ ក្នុងករណីដែល ខ្ញុំបាទ-នាងខ្ញុំ មិនគោរពតាមបទបញ្ជាខាងលើនេះ ខ្ញុំបាទ-នាងខ្ញុំ សុខចិត្តឱ្យអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការដូចជា ការផ្អាកការដ្ឋាន មិនឱ្យចូលស្នាក់នៅ មិនផ្តល់កម្មសិទ្ធិ មិនឱ្យបើកអាជីវកម្ម ឬ កសាងសំណុំឯកសារបញ្ជូនទៅតុលាការ ដើម្បីពិនិត្យវិនិច្ឆ័យ ករណីខុសឆ្គងនឹងច្បាប់ជាធរមាន ។

.......... ថ្ងៃទី ................ ខែ .......... ឆ្នាំ ............

**ស្នាមមេដៃស្តាំ**

លេខ : ..................

**បានឃើញ និង យល់ព្រម**

................ថ្ងៃទី ............ ខែ ............ ឆ្នាំ ................

**អភិបាល ក្រុង-ស្រុក.......**

ក្រដាស A3

| 10 | 20 | 100 | 35 | 55 | | 20 | 20 | 70 | 50 |
|---|---|---|---|---|---|---|---|---|---|
| ល.រ | ថ្ងៃ ខែ ឆ្នាំ | កំណែ | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ឈ្មោះ-មុខងារ | | ហត្ថលេខា | ថ្ងៃ ខែ ឆ្នាំ | ទីតាំងសុំសាងសង់ : | ម្ចាស់សំណង់: |
| | | | | គូរដោយ | | | | | |
| | | | | គណនាដោយ | | | | ឈ្មោះគម្រោង : | |
| | | | | សិក្សាដោយ | | | | | |
| | | | | ពិនិត្យដោយ | | | | ឈ្មោះប្លង់ : | មាត្រដ្ឋាន / ចំនួនសន្លឹក / លេខសន្លឹក |
| | | | | យល់ព្រមដោយ | | | | | |

42

# ឧបសម្ព័ន្ធទី២

# សំណុំឯកសារនៃពាក្យសុំលិខិត
# អនុញ្ញាតបើកការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ .................................................. ភេទ ............អាយុ............ ឆ្នាំ សញ្ជាតិ ............................ ថ្ងៃខែឆ្នាំ ...................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនលេខ ........................................... មុខរបរ...........................................................អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ........................................... ផ្លូវលេខ ..................ក្រុមទី .............. ភូមិ...................... ឃុំ/សង្កាត់...................................ស្រុក /ក្រុង........................... ខេត្ត ............................ ទូរសព្ទលេខ ..................... .................. ទូរសារលេខ........ .................................................. ។

## សូមគោរពជូន

**លោក អភិបាលក្រុង** ...................................................

**កម្មវត្ថុ** : សំណើសុំលិខិតអនុញ្ញាតបើកការដ្ឋាន ....................................................ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ ....................................ផ្លូវលេខ ...................... ក្រុមទី ........................ ភូមិ ........................... សង្កាត់ ................................ ក្រុង....................................... ខេត្ត ................................................. ។

**យោង** : លិខិតអនុញ្ញាតសាងសង់លេខ ......................... ចុះថ្ងៃទី .............ខែ ............ ឆ្នាំ ............... របស់សាលាក្រុង ........................................................................ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកអភិបាលក្រុងមេត្តាផ្តល់ឱ្យខ្ញុំបាទ-នាងខ្ញុំ នូវលិខិតអនុញ្ញាតបើកការដ្ឋាន ................................................ ដែលមានទីតាំងដូចជម្រាបជូនខាងលើដោយក្តីអនុគ្រោះ ។

ខ្ញុំបាទ-នាងខ្ញុំសូមសន្យាថា អនុវត្តទៅតាមបទបញ្ជាដូចមានចែងក្នុងគម្រោងប្លង់ដែលបានអនុញ្ញាត ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

សូមលោកអភិបាលក្រុង មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ ។

........................ ថ្ងៃទី ......... ខែ ..........ឆ្នាំ ..........

**ស្នាមមេដៃស្តាំម្ចាស់សំណង់**

ព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការត្រួតពិនិត្យសំណុំឯកសារសំរាប់សុំលិខិតអនុញ្ញាតបើកការដ្ឋាន

១- ឈ្មោះម្ចាស់សំណង់ .............................................. អាយុ............ឆ្នាំ ភេទ............. សញ្ជាតិ.............................

២- ប្រភេទសំណង់ ..........................................................................................................................................

៣- ទីតាំងស្នើសុំសាងសង់ : ដីឡូត៍លេខ ...................................... ផ្ទៃ.................................... $ម^2$ ផ្លូវលេខ.................

ភូមិ............................ សង្កាត់.............................. ក្រុង................................. ខេត្ត ....................................

៤- លិខិតអនុញ្ញាតសាងសង់របស់សាលាក្រុង មាន ☐ គ្មាន ☐

- សុពលភាពលិខិតអនុញ្ញាតសាងសង់ មិនទាន់ផុតកំណត់ ☐ ផុតកំណត់ ☐

៥- កិច្ចសន្យារវាងម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់ មាន ☐ គ្មាន ☐

៦- វិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់របស់ក្រុមហ៊ុនសាងសង់

ឬក្រុមជាងម៉ៅការសាងសង់ មាន ☐ គ្មាន ☐

៧- ឯកសារពាក់ព័ន្ធរួមមាន :
- ប្លង់ស្ថាបត្យកម្ម មាន ☐ គ្មាន ☐
- ប្លង់គ្រឿងផ្គុំសំណង់ មាន ☐ គ្មាន ☐
- សញ្ញាបត្រវិស្វករគណនាគ្រឿងផ្គុំសំណង់ មាន ☐ គ្មាន ☐
- របាយការណ៍សិក្សាពិសោធន៍ដី មាន ☐ គ្មាន ☐
- ..........................................................................................................
- ..........................................................................................................

៨- យោបល់ជំនាញក្នុងការបើកការដ្ឋាន : អនុញ្ញាត ☐ មិនអនុញ្ញាត ☐

<u>មូលហេតុ</u> : ..........................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

មន្ត្រីត្រួតពិនិត្យ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## ស្តីពី

## ការចុះត្រួតពិនិត្យការដ្ឋាន ..............................................................

១- ឆ្នាំ............................ ខែ......................... ថ្ងៃទី ............................ វេលាម៉ោង ................................................

២- នៅ : ..................................................................................................................................................

៣- មានការត្រួតពិនិត្យការដ្ឋានសំណង់ស្ថិតនៅលើដីឡូត៍លេខ ................................................................................

..............................................................................................................................................................

..............................................................................................................................................................

៤- ក្រោមការដឹកនាំការងាររបស់លោក .................................................................................................

..............................................................................................................................................................

៥- សមាសភាពចូលរួម : ...........................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

៦- លទ្ធផលនៃការត្រួតពិនិត្យ :

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

៧- ការងារត្រួតពិនិត្យការដ្ឋានសាងសង់ខាងលើបានចប់សព្វគ្រប់នៅម៉ោង ............នៃថ្ងៃទី ខែ ឆ្នាំ ដដែល។

**បានឃើញ និងឯកភាព**

..................... ថ្ងៃទី ............... ខែ............... ឆ្នាំ ................

**ប្រធានក្រុមការងារ**

**អ្នកធ្វើកំណត់ហេតុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុង .....................................

លេខ :..............................................

# លិខិតអនុញ្ញាតបើកការដ្ឋាន

**យោង :** លិខិតអនុញ្ញាតសាងសង់លេខ ..................................... ចុះថ្ងៃទី ............. ខែ ....................ឆ្នាំ.........................

របស់សាលាក្រុង ..................................................................................................................................

- ប្លង់គ្រឿងផ្គុំសំណង់
- កំណត់ហេតុ .........................................................................................................................................
- ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន ចុះថ្ងៃទី .............. ខែ .................... ឆ្នាំ ..................... ។

**សាលាក្រុង** ..............................................................................

**អនុញ្ញាតជូន**

លោក-លោកស្រី .......................................................... ភេទ ............. អាយុ ..............ឆ្នាំ សញ្ជាតិ .....................

មុខរបរ ....................................................... ជាម្ចាស់សំណង់ ...............................................................................

ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ ......................................... ផ្លូវលេខ ...................... ភូមិ ...............................................

សង្កាត់............................................ ក្រុង.................................................. ខេត្ត ...............................................................

នូវលិខិតអនុញ្ញាតបើកការដ្ឋាន ................................................................ ដូចខាងលើជាផ្លូវការចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម្ចាស់សំណង់ និងក្រុមហ៊ុនសាងសង់ ឬក្រុមជាងម៉ៅការសាងសង់ត្រូវគោរពបទបញ្ជាដូចបានចែងក្នុងគម្រោងប្លង់ដែលបានអនុញ្ញាត បទបញ្ជា ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**អភិបាលក្រុង**

**ចម្លងជូន**

- សាលាខេត្ត ................
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត.................................
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង.......................
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

# សំណុំឯកសារនៃពាក្យសុំលិខិតបើកការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំលិខិតបិទការដ្ឋាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ .................................................. ភេទ ...........អាយុ.............. ឆ្នាំ សញ្ជាតិ ............................
ថ្ងៃខែឆ្នាំកំណើត.........................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនលេខ ..........................................
មុខរបរ...................................................................អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នផ្ទះលេខ ....................................................
ផ្លូវលេខ ...................ក្រុមទី .............. ភូមិ.......................... ឃុំ/សង្កាត់..........................ស្រុក/ក្រុង...................................
ខេត្ត ............................. ទូរសព្ទលេខ ...................... ................ ទូរសារលេខ........ ............................................... ។

## សូមគោរពជូន

**លោក អភិបាលក្រុង** ...........................................................................

**កម្មវត្ថុ** : សំណើសុំលិខិតបិទការដ្ឋាន ..................................................ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ
.................................ផ្លូវលេខ .................... ក្រុមទី ............... ភូមិ ..............................សង្កាត់.......................................
ក្រុង .................................... ខេត្ត ...................................... ។

**យោង** : លិខិតអនុញ្ញាតសាងសង់លេខ ............................. ចុះថ្ងៃទី .............ខែ ............. ឆ្នាំ .................
របស់សាលាក្រុង ....................................................................................... ។
- លិខិតអនុញ្ញាតបើកការដ្ឋានលេខ ........................... ចុះថ្ងៃទី .............ខែ ............. ឆ្នាំ .................
របស់សាលាក្រុង ....................................................................................... ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបលោកអភិបាលក្រុងមេត្តាផ្តល់ឱ្យខ្ញុំបាទ-នាងខ្ញុំ នូវលិខិតបិទការដ្ឋាន ............................................................ ដែលមានទីតាំងដូចជម្រាបជូនខាងលើដោយក្តីអនុគ្រោះ ។

សូមលោកអភិបាលក្រុង មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ ។

...................... ថ្ងៃទី ........ខែ ...........ឆ្នាំ ..........

**ស្នាមមេដៃស្តាំម្ចាស់សំណង់**

ព្រះរាជាណាចក្រកម្ពុជា ... ៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការត្រួតពិនិត្យសំណុំឯកសារសម្រាប់សុំលិខិតបិទការដ្ឋាន

១- ឈ្មោះម្ចាស់សំណង់ ............................................ អាយុ...........ឆ្នាំ ភេទ............ សញ្ជាតិ...............................

២- ប្រភេទសំណង់ ..........................................................................................................................................

៣- ទីតាំងស្នើសុំសាងសង់ : ដីឡូត៍លេខ ..................................... ផ្ទៃ.................................... ម² ផ្លូវលេខ............

ភូមិ.............................. សង្កាត់......................................... ក្រុង .......................... ខេត្ត ..................................

| | | |
|---|---|---|
| ៤- លិខិតអនុញ្ញាតសាងសង់របស់សាលាក្រុង | មាន ☐ | គ្មាន ☐ |
| - សុពលភាពលិខិតអនុញ្ញាតសាងសង់ | មិនទាន់ផុតកំណត់ ☐ | ផុតកំណត់ ☐ |
| ៥- លិខិតអនុញ្ញាតបើកការដ្ឋានរបស់សាលាក្រុង | មាន ☐ | គ្មាន ☐ |
| ៦- ឯកសារពាក់ព័ន្ធរួមមាន : - ប្លង់ស្ថាបត្យកម្ម | មាន ☐ | គ្មាន ☐ |
| - ប្លង់គ្រឿងផ្គុំសំណង់ | មាន ☐ | គ្មាន ☐ |
| - ក្រុមហ៊ុនម៉ៅការសាងសង់ ឬក្រុមជាង | មាន ☐ | គ្មាន ☐ |
| - បញ្ហាទំនាស់ | មាន ☐ | គ្មាន ☐ |

- បញ្ហាផ្សេងៗ ..........................................................................................
- ..........................................................................................................
- ..........................................................................................................

៧- យោបល់ជំនាញក្នុងការបិទការដ្ឋាន : អនុញ្ញាត ☐ មិនអនុញ្ញាត ☐

<u>មូលហេតុ</u> : .......................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

ភ្នាក់ងារត្រួតពិនិត្យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

## ស្ដីពី

## ការចុះត្រួតពិនិត្យការដ្ឋាន ..................................................

១- ឆ្នាំ............................ ខែ.......................... ថ្ងៃទី ............................... វេលាម៉ោង ..........................................

២- នៅ : ..........................................................................................................................................................

៣- មានការត្រួតពិនិត្យការដ្ឋានសំណង់ស្ថិតនៅលើដីឡូត៍លេខ ..................................................................................

..........................................................................................................................................................

..........................................................................................................................................................

៤- ក្រោមការដឹកនាំការងាររបស់លោក ..........................................................................................................

..........................................................................................................................................................

៥- សមាសភាពចូលរួម : ......................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

៦- លទ្ធផលនៃការត្រួតពិនិត្យ :

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

៧- ការងារត្រួតពិនិត្យការដ្ឋានសាងសង់ខាងលើបានចប់សព្វគ្រប់នៅម៉ោង ........... នៃថ្ងៃទី ខែ ឆ្នាំ ដដែល។

អ្នកធ្វើកំណត់ហេតុ

បានឃើញ និងឯកភាព

..................... ថ្ងៃទី ........... ខែ ..............ឆ្នាំ .................

ប្រធានក្រុមការងារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុង ......................................
លេខ :............................................

# លិខិតបិទការដ្ឋាន

**យោង :** លិខិតអនុញ្ញាតសាងសង់លេខ ........................................ ចុះថ្ងៃទី .............. ខែ ............ឆ្នាំ............................
របស់សាលាក្រុង ...................................................................................................................................
- លិខិតអនុញ្ញាតបើកការដ្ឋានលេខ ......................................ចុះថ្ងៃទី .............. ខែ .................... ឆ្នាំ .....................
- ប្លង់គ្រឿងផ្គុំសំណង់
- កំណត់ហេតុ ..................................................................................................................................................
- ពាក្យសុំលិខិតបិទការដ្ឋាន ចុះថ្ងៃទី ................ ខែ...................... ឆ្នាំ .................... ។

**សាលាក្រុង** .........................................................................

**ផ្តល់ជូន**

លោក-លោកស្រី ............................................. ភេទ ................. អាយុ ....................ឆ្នាំ សញ្ជាតិ .....................
មុខរបរ ....................................... ជាម្ចាស់សំណង់ ........................................................ ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ
..................................... ផ្លូវលេខ .................... ភូមិ ............................. សង្កាត់...........................................
ក្រុង............................................ ខេត្ត ..................................... នូវលិខិតបិទការដ្ឋាន ..................................................
ដូចខាងលើជាផ្លូវការចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដើម្បីប្រើប្រាស់តាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

**អភិបាលក្រុង**

**<u>ចម្លងជូន</u>**
- សាលាខេត្ត ................
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត................................
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង.......................
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤

# សោហ៊ុយលើសេវាសំណាក់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងកំណត់សោហ៊ុយលើសេវាសំណង់
## សម្រាប់ក្រុងតាខ្មៅខេត្តកណ្តាល ក្រុងស្ទឹងសែនខេត្តកំពង់ធំ ក្រុងក្រចេះខេត្តក្រចេះ ក្រុងព្រះសីហនុខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ក្រុងសួងខេត្តកំពង់ចាម ស្រុកតាមរក៏ខេត្តព្រៃវែង

ដើម្បីបម្រើសេវាសាធារណៈឱ្យមានតម្លាភាព និងសមស្របទៅនឹងជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួងបានកំណត់សោហ៊ុយលើសេវាសំណង់ក្នុងការពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល លិខិតអនុញ្ញាតបើកការដ្ឋាន លិខិតបិទការដ្ឋាន ឬ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ ដូចតទៅ :

## I. សំណង់លំនៅឋាន

| ល.រ | វាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ក ពាក្យសុំ | ខ តែម | គ បង្កាន់ដៃទទួលពាក្យ | ឃ. ផ្ទៃក្រឡាកម្រាលសំណង់ | | | | | |
| | | | | | ≤១០០ម² | ≤២០០ម² | ≤៣០០ម² | ≤៤០០ម² | ≤៥០០ម² | |
| **ក. លិខិតអនុញ្ញាតសាងសង់** | | | | | | | | | | |
| ១ | *ភូមិគ្រឹះ* | ២០០០ | ២០០០ | ៥០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | ១៨០០០០ | ២០០០០០ | ក+ខ+គ+ឃ |
| ២ | *ផ្ទះល្វែង* | ២០០០ | ២០០០ | ៥០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | |
| ៣ | *ថ្មក្រោម ឈើលើ* | ២០០០ | ២០០០ | ៥០០ | ៤០០០០ | ៦០០០០ | ៨០០០០០ | ១០០០០០ | ១២០០០០ | |
| **ខ លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល** | | | | | | | | | | |
| ១ | *ភូមិគ្រឹះ* | ២០០០ | ២០០០ | ៥០០ | ៨០០០០ | ១០០០០០ | ១២០០០០ | ១៤០០០០ | ១៦០០០០ | |
| ២ | *ផ្ទះល្វែង* | ២០០០ | ២០០០ | ៥០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១២០០០០ | |
| ៣ | *ថ្មក្រោម ឈើលើ* | ២០០០ | ២០០០ | ៥០០ | ២០០០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | |
| **គ. លិខិតអនុញ្ញាតបើកការដ្ឋាន** | | | | | | | | | | |
| ១ | *ភូមិគ្រឹះ* | ២០០០ | ២០០០ | ៥០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | |
| ២ | *ផ្ទះល្វែង* | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | |
| ៣ | *ថ្មក្រោម ឈើលើ* | ២០០០ | ២០០០ | ៥០០ | ៥០០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | |
| **ឃ. លិខិតបិទការដ្ឋាន ឬ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ** | | | | | | | | | | |
| ១ | *ភូមិគ្រឹះ* | ២០០០ | ២០០០ | ៥០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤០០០០ | ៤៥០០០ | |
| ២ | *ផ្ទះល្វែង* | ២០០០ | ២០០០ | ៥០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ | |
| ៣ | *ថ្មក្រោម ឈើលើ* | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | |

## II. សំណង់របង

| ល.រ | រាយមុខសេវាកម្ម | សោហ៊ុយសេវា (គិតជាប្រាក់រៀល) | | | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ក ពាក្យសុំ | ខ តែម | គ បង្កាន់ដៃទទួលពាក្យ | ឃ. ផ្ទៃក្រឡាកម្រាលសំណង់ | | | | | | |
| | | | | | ≤២០ម | ≤២០០ម | ≤៥០០ម | ≤១០០០ម | ≤៥០០០ម | >៥០០០ម | |
| ១ | *លិខិតអនុញ្ញាតសាងសង់និងជួសជុលរបង* | ២០០០ | ២០០០ | ៥០០ | ២០០០០ | ៤០០០០ | ៦០០០០ | ៨០០០០ | ១០០០០០ | ១៥០០០០ | ក+ខ+គ+ឃ |
| ២ | *លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់និងជួសជុលរបង* | ២០០០ | ២០០០ | ៥០០ | ៥០០០ | ៨០០០ | ១១០០០ | ១៤០០០ | ១៧០០០ | ៣០០០០ | |
| ៣ | *លិខិតបិទការដ្ឋានសាងសង់ និងជួសជុលរបង* | ២០០០ | ២០០០ | ៥០០ | ១០០០០ | ១៥០០០ | ២០០០០ | ២៥០០០ | ៣០០០០ | ៦០០០០ | |

**កំណត់សម្គាល់ :**

- ផ្ទៃក្រឡាកម្រាលសំណង់ ដែលត្រូវយកសោហ៊ុយលើសេវាសំណង់ ចំពោះការសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល គឺត្រូវកំណត់យកតែផ្ទៃក្រឡាកម្រាលសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល ដោយមិនបូកបញ្ចូលនូវផ្ទៃក្រឡាកម្រាលសំណង់ដែលមានស្រាប់ទេ ។
- លិខិតអនុញ្ញាតសាងសង់ សាងសង់ពង្រីកបន្ថែម ជួសជុល រុះរើ មានសុពលភាពរយៈពេល ០១ឆ្នាំ និងអាចពន្យារពេលបានម្តង ។